**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**
**លេខ: ១៤២/២៣.........អអរ**

## សេចក្តីប្រកាសព័ត៌មាន
## លទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី "ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តកណ្តាល"

នាព្រឹកថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តកណ្តាល»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តម គង់ សោភ័ណ្ឌ អភិបាលនៃគណៈអភិបាលខេត្តកណ្តាល**
- **មន្ទីរអង្គភាពជំនាញជុំវិញរដ្ឋបាលខេត្តកណ្តាល**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងពន្យល់ និងផ្សព្វផ្សាយដល់សាធារណជនឱ្យបានជ្រាបច្បាស់អំពី យន្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងភាពជោគជ័យដែលរដ្ឋបាលខេត្តកណ្តាល ខិតខំប្រឹងប្រែងអនុវត្ត ព្រមទាំងសម្រេចបានសមិទ្ធផលវិជ្ជមាន ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ប្រកបដោយថាមពលរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

### I. ស្ថានភាពទូទៅ

ខេត្តកណ្តាល បែងចែកចេញជា ក្រុង៣ ស្រុក១០ ឃុំ១០១ សង្កាត់២៦ និង១.០១០ភូមិ ដែលមានប្រជាពលរដ្ឋរស់នៅសរុប ១.៣៤៨.៨៥១នាក់ ស្មើនឹង ៣០៧.៧០៦គ្រួសារ ក្នុងនោះ មុខរបរចម្បងរបស់ប្រជាពលរដ្ឋពឹងផ្អែកទៅលើ វិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម។ សេដ្ឋកិច្ចខេត្តមានទំហំប្រមាណ ១១.២៥២.៦៥៥ពាន់រៀល ស្មើនឹង ៤% នៃសេដ្ឋកិច្ចជាតិ ដោយក្នុង ចំណូលជាមធ្យមសម្រាប់មនុស្សម្នាក់ៗ ស្មើនឹង ២.០៦៤ដុល្លារអាមេរិក អត្រាភាពក្រីក្រ ត្រូវបានថយចុះមកត្រឹម ៣,៦៨%។

## II. សមិទ្ធផលការងារ

ក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ(២០១៨-២០២២) សមិទ្ធផលការងារសំខាន់ៗ ដែលសម្រេចបានរួមមាន៖

- **វិស័យគាំពារសង្គម៖** រដ្ឋបាលខេត្ត បានអនុវត្តនូវគោលនយោបាយគាំពារសង្គរបស់រាជរដ្ឋាភិបាល ដោយបានឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ ងាយរងគ្រោះ និងស្លាប់ដោយសារជំងឺកូវីដ-១៩ រួមទាំងស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ, ឧបត្ថម្ភជូនគ្រួសារងាយរងហានិភ័យដោយសារសម្ពាធអតិផរណា និងគ្រោះទឹកជំនន់ សរុបចំនួន ៧៥,៩៨៧គ្រួសារ ចំណាយទឹកប្រាក់ ២០៦.៨៣៥.៦៩៦. ៩០០រៀល។
- **វិស័យកសិកម្ម៖** អាស្រ័យដោយសេដ្ឋកិច្ចពឹងផ្អែកលើការងារកសិកម្មជាចម្បង រដ្ឋបាលខេត្ត បានយកចិត្តទុកដាក់ខ្ពស់ ដោយបានបានកំណត់ចក្ខុវិស័យច្បាស់លាស់ក្នុងការធ្វើទំនើបកម្មវិស័យកសិកម្ម ឱ្យកាន់តែមានភាពប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ មាននិរន្តរភាព និងកាត់បន្ថយថ្លៃដើមផលិតកម្ម តាមរយៈការផ្តល់នូវបច្ចេកទេសជូនដល់កសិករ បង្កើនប្រាក់ចំណូលគ្រួសារកសិករ ប្រកបដោយវិបុលភាព និងសុខមាលភាព ព្រមទាំងមានគោលដៅធ្វើពិពិធកម្មវិស័យកសិកម្មខេត្ត ទៅជាកសិ-ទេសចរ និងកសិ-ឧស្សាហកម្ម។ ខេត្តបាន ចងក្រងបណ្តុំអាជីវកម្មបន្លែសុវត្ថិភាពបានចំនួន ៧៥បណ្តុំ និងបណ្តុះបណ្តាលសមាជិកបណ្តុំបាន ៣,៥៣២នាក់ ព្រមទាំងបានដាក់ចេញផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍមាសបៃតងខេត្តកណ្តាល (២០២៣-២០៣០) ដែលជាត្រីវិស័យសម្រាប់ផលិតកម្មបន្លែ និងផ្លែឈើប្រកបសុវត្ថិភាព និងគុណភាព ធានាបាននូវសុខុមាលភាពអ្នកប្រើប្រាស់ជាសំខាន់។
- **ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ៖** ដោយមានការរួមសហការគ្នាពីថ្នាក់ដឹកនាំគណៈបញ្ជាការឯកភាពខេត្ត ប្រជាការពារ និងប្រជាពលរដ្ឋទាំងអស់ ទូទាំងខេត្តរក្សាបាននូវសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈបានយ៉ាងល្អប្រសើរ បទល្មើសគ្រប់ប្រភេទមានការថយចុះ។ ជាក់ស្តែងក្នុងឆ្នាំ២០២២ បទល្មើសមានការថយចុះ ៧៨% ប្រតិបត្តិការបង្ក្រាបសម្រេចបាន ៩៦%។ ជាមួយគ្នានេះ ការអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ទទួលបានលទ្ធផលគួរជាទីមោទនៈ ដោយការប្រលងប្រណាំង ទទួលបានជ័យលាភីចំណាត់ថ្នាក់លេខ១ មានចំនួន ១១៨ឃុំ-សង្កាត់ និងចំណាត់ថ្នាក់ប្រភេទលេខ២ ចំនួន ៩ឃុំ-សង្កាត់។
- **ការផ្តល់សេវាសាធារណៈ៖** រដ្ឋបាលខេត្ត បាននិងកំពុងជំរុញ និងគាំទ្រការផ្តល់សេវាសាធារណៈតាមរយៈយន្តការច្រកចេញចូលតែមួយខេត្ត, ការិយាល័យច្រកចេញចូលតែមួយក្រុង-ស្រុក និងឃុំ-សង្កាត់ ក្នុងន័យលើកកម្ពស់គុណភាព ប្រសិទ្ធិភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាពនៃការផ្តល់សេវាជូនប្រជាពលរដ្ឋ។ យន្តការនេះ បានផ្តល់សេវាជូនប្រជាពលរដ្ឋ សរុបចំនួន ១៥៦,៣៧៥សេវា ទទួលបានចំណូលសរុប ២៩.៥៦៧.៤៨១.៥០០រៀល។

- **ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ៖** រដ្ឋបាលខេត្ត បានខិតខំអភិវឌ្ឍន៍ទៅលើហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់តភ្ជាប់ពីទីរួមខេត្ត ទៅកាន់គ្រប់បណ្តាភូមិទាំងអស់ សំដៅចូលរួមចំណែកយ៉ាងសំខាន់ជម្រុញកំណើនសេដ្ឋកិច្ច សម្រួលដល់ចរាចរណ៍ ការដឹកជញ្ជូនទំនិញ អ្នកដំណើរ ទេសចរណ៍ព្រមទាំងកសិផល និងផលិតផលកសិឧស្សាហកម្មផ្សេងៗជាច្រើន ទៅកាន់ទីផ្សារឱ្យកាន់តែឆាប់រហ័ស និងចំណាយតិច។ ចំពោះការផ្គត់ផ្គង់ទឹកស្អាត គឺបានតភ្ជាប់បណ្តាញដែលគ្របដណ្តប់លើ ៩៨៥ភូមិ ចំណែកបណ្តាញអគ្គិសនី បានគ្របដណ្តប់លើ ១.០១០ភូមិ ពោលគឺប្រជាពលរដ្ឋមានអគ្គិសនីប្រើប្រាស់ ១០០%។
- **ការងារអប់រំ និងបណ្តុះបណ្តាលធនធានមនុស្ស៖** រដ្ឋបាលខេត្ត បានលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្ស ដែលជាគោលដៅអាទិភាព ផ្តល់ឱកាសស្មើៗគ្នាដល់យុវជនក្នុងការអភិវឌ្ឍសមត្ថភាព ពិសេស ខេត្តបានយកចិត្តទុកដាក់ក្នុងការអប់រំលើកុមារអូទីស្សឹម ពីកំរិតបឋមសិក្សាដល់វិទ្យាល័យ។ ក្នុងឆ្នាំសិក្សា២០២១-២០២២ មានសិស្សានុសិស្សប្រលងជាប់មធ្យមសិក្សាទុតិយភូមិចំនួន ៧៥.៩៥% ក្នុងនោះ សិស្សនិទ្ទេសA សរុប១០៨នាក់។ ជាមួយគ្នានេះ រដ្ឋបាលខេត្ត ក៏បានជំរុញឱ្យប្រជាពលរដ្ឋមានការងារសមរម្យ និងកម្រិតជីវភាពកាន់តែប្រសើរឡើង, លើកកម្ពស់សេចក្តីថ្លៃថ្នូរបស់ប្រជាពលរដ្ឋ, បង្កើនបាននូវកម្លាំងពលកម្ម ឬធនធានមនុស្សប្រកបដោយចំណេះដឹង សមត្ថភាព ជំនាញវិជ្ជាជីវៈការងារ ផលិតភាពខ្ពស់ និងមានលក្ខណៈប្រកួតប្រជែងសម្រាប់ការងារពេញមួយជីវិត តាមរយៈការបង្កើតឱ្យមានមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ពង្រឹងសមត្ថភាព តម្រង់ទិសដល់ប្រជាពលរដ្ឋ ដើម្បីអាចឈានជើងចូលទីផ្សារការងារបានល្អប្រសើរ។

## III. ទិសដៅការងារបន្ត

រដ្ឋបាលខេត្ត បានប្តេជ្ញាបន្តថែរក្សាការពារឱ្យបាននូវសុខសន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពក្នុងសង្គម ដោយបន្តពង្រឹងការអនុវត្តគោលនយោបាយភូមិឃុំ-សង្កាត់ មានសុវត្ថិភាព បន្តបង្កើនការផ្សព្វផ្សាយ ទប់ស្កាត់ បង្ក្រាប បទល្មើសគ្រប់ប្រភេទ និងបន្តជំរុញការផ្តល់សេវាសាធារណៈ ឱ្យកាន់តែមានលក្ខណៈល្អប្រសើរឡើង។ បន្តបង្កើនកិច្ចការដឹកនាំសហការសម្របសម្រួលជាមួយកងកម្លាំងមានសមត្ថកិច្ច ដែលឈរជើងនៅតាមតំបន់ ព្រំដែនគ្រប់ថ្នាក់ ដើម្បីថែរក្សា និងការពារបូរណភាពទឹកដី អធិបតេយ្យភាពជាតិ និងពង្រឹងការគ្រប់គ្រងការចេញចូលឆ្លងព្រំដែន ទាំងមនុស្ស និងទំនិញ។ បន្តជំរុញការងារបង្កបង្កើនផលស្រូវ គ្រប់រដូវ និងធ្វើពិពិធកម្មកសិកម្ម ការចិញ្ចឹមសត្វ ជាពិសេសការអនុវត្តតាមផែនការអភិវឌ្ឍមាសបៃតងរបស់ខេត្ត និងជំរុញនូវការផ្គត់ផ្គង់ទឹកស្អាតឱ្យបានគ្រប់ភូមិទាំងអស់។/.

ថ្ងៃព្រហស្បតិ៍ ៩កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣